ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
លេខ: ០១១ គ.ស.ច.គ.

ភ្នំពេញ, ថ្ងៃទី ១ ខែ ៥ ឆ្នាំ ២០០៧

# សេចក្តីសម្រេច
## ស្តីពី
## និមិត្តសញ្ញា របស់ គ.ស.ច.គ.

### រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
### និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧/០៤/១២៤ចុះថ្ងៃទី១៥ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៧/០០៧ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ-បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- យោងការសម្រេចរបស់អង្គប្រជុំលើកទី៣ នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧
- យោងតាមការចាំបាច់របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ។

## ស ម្រេ ច

**ប្រការ ១** : បង្កើតនិមិត្តសញ្ញា (LOGO) តំណាងអោយគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់ប្រើប្រាស់ជាផ្លូវការនៅលើលិខិតស្នាម សៀវភៅ បដា ពាក្យស្លោក។ល។ ទាំងភាសាខ្មែរ ឬភាសាបរទេស ក្នុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២** : និមិត្តសញ្ញា ( LOGO ) ដែលមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយនេះ មានអត្ថន័យនៃខ្លឹមសាររូបភាព និង ទំហំ ដូចខាងក្រោម :

១- និមិត្តសញ្ញា ( LOGO ) នេះ មានរាងមូល ដែលមានបន្ទាត់ផ្ចិតប្រវែង ៥៥ មីលីម៉ែត្រ ។

២- មានជាយព័ទ្ធជុំវិញមួយជាន់ ដែលមានទទឹងប្រវែង ៨ មីលីម៉ែត្រ ផ្ទៃខាងក្នុងមានពណ៌ផ្ទៃមេឃ ។ នៅក្នុងផ្ទៃនោះ មានរូបកញ្ចុំផ្កាមានត្របកស្លឹកផ្កាចំនួនប្រាំមួយ ហើយចែកជាពីរផ្នែក គឺ :

ក- ផ្នែកខាងលើមានសរសេរអក្សរកាត់ថា "គ.ស.ច.គ." មានន័យថាគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ។

ខ- ផ្នែកខាងក្រោមមានសរសេរអក្សរឡាតាំង ថា " N R S C " មានន័យថា National Road Safety Committee ។

៣- នៅក្នុងរង្វង់មូលខាងក្នុងមានរូបភាព ដូចខាងក្រោម :

ក- មានផ្ទៃពណ៌ប្រផេះ ដែលជាពណ៌តំណាងឱ្យផ្លូវថ្នល់ ។

ខ- ផ្នែកខាងលើ មានរូបទង់ជាតិខ្មែរ ដែលបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជា ។

គ- មានគំនូសដាច់ៗពណ៌លឿង គូសត្រង់ចាប់ពីផ្នែកខាងក្រោមទង់ជាតិ មកដល់បាតដៃទ្រខាងក្រោម ដែលជាគំនូសបែងចែកទ្រូងផ្លូវជាពីរទិសចរាចរណ៍ ។

ឃ- គំនូស ស ជាប់ពីរខ្សែដែលគូសចាប់ផ្តើមចេញពីចំណុចចុងគំនូសដាច់ៗ ពណ៌លឿង ចាប់ផ្នែកខាងក្រោមទង់ជាតិ គូសត្រង់មកចុងម្រាមដៃទាំងសងខាងជាគំនូសកំណត់គែមចិញ្ចើម ផ្លូវ ឬ ជាយផ្លូវ ។

ង- នៅផ្នែកខាងក្រោមមានបាតដៃពណ៌ ស ពីរផ្គុំគ្នា ទ្រមនុស្សពីរនាក់កំពុងដើរដឹកដៃកូនក្មេងដើរនៅលើ គំនូសពណ៌ ស សម្រាប់ថ្មើរជើងឆ្លងកាត់ ដែលបញ្ជាក់ពីការយកចិត្តទុកដាក់ដល់ សុវត្ថិ-ភាពចំពោះថ្មើរជើង ។

ច- នៅផ្នែកខាងស្តាំនៃគំនូសពណ៌ ស ជាប់មានរថយន្តដឹកអ្នកដំណើរនៅខាងលើនិង ទោចក្រយានយន្តនៅពីក្រោម ដែលបញ្ជាក់ពីការយកចិត្តទុកដាក់ដល់សុវត្ថិភាពចំពោះអ្នកធ្វើដំណើរដោយរថយន្តដឹកអ្នកដំណើរ និង ទោចក្រយានយន្ត ។ល ។

ឆ- នៅផ្នែកខាងឆ្វេងនៃគំនូសពណ៌ ស ជាប់ មានរថយន្តដឹកទំនិញនៅខាងលើ និង រថយន្តធុនទេសចរណ៍

នៅពីក្រោមដែលបញ្ជាក់ពីការយកចិត្តទុកដាក់ ដល់សុវត្ថិភាពចំពោះការដឹកជញ្ជូនទំនិញដោយរថយន្តដឹកទំនិញ ធុនធ្ងន់ និង ការធ្វើដំណើរដោយរថយន្តធុនទេសចរណ៍ ។ល។

**ប្រការ ៣ :** សមាជិក សមាជិកា នៃគណៈកម្មាធិការជាតិ និងខេត្ត-ក្រុង អគ្គលេខាធិការដ្ឋាន នៃ គ.ស.ច.គ និង លេខាធិការដ្ឋានខេត្ត-ក្រុង ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**និងជា ប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក**

ស៊ុន ចាន់ថុល

**<u>ចម្លងជូន</u> :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

-គ្រប់សមាជិក នៃ គ.ស.ច.គ

-គណៈកម្មាធិការជាតិ សុវត្ថិភាព ចរាចរណ៍ផ្លូវគោកខេត្ត-ក្រុង

"**ដើម្បីជូនជ្រាប**"

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## ស្តីពី

## និមិត្តសញ្ញាតំណាងគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

